# វាលភក់បាសិត **A1**



| | | |
|---|---|---|
| **ខេត្ត** | : | កណ្ដាល និង រាជធានីភ្នំពេញ |
| **ស្រុក** | : | ពញាឮ  អង្គស្នួល និង ដង់កោ |
| **ផ្ទៃដី ( ហិកតា)** | : | ២.៧៧០ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ៤ ដល់ ១០ |
| **កូអរដោនេចំណុចកណ្ដាល** | : | ១១$^{0}$ ៣៩' ជ   ១០៤$^{0}$ ៥០' ក |

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានតំបន់វាលភក់បាសិតដែលជាបឹងមួយមានទឹកជាអចិន្ត្រៃយ៍ ស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ ៥ប្រហែល១២គីឡូម៉ែត្រភាគខាងជើងនៃរាជធានីភ្នំពេញ ។ បណ្ដាតំបន់ដែលនៅជុំវិញបឹងនេះត្រូវលិចទឹកជំនន់នៅក្នុងរដូវវស្សា ដែលបង្កើតបានជាវាលភក់មានវិសាលភាពធំល្វឹងល្វើយ ។ តំបន់វាលភក់នេះព័ទ្ធជុំវិញដោយដីកសិកម្ម ជាពិសេសដីស្រែ ។ ទុងប្រផេះមួយចំនួនតូច និង ស្មោញ មានវត្តមានទៀងទាត់ក្នុងតំបន់នេះនៅរដូវវស្សា ។ តំបន់នេះត្រូវបានគេដឹងផងដែរថា បានទ្រទ្រង់ប្រភេទរំពេទន្លេ (River Tern *Sterna aurantia*) នៅរដូវវស្សា ជានិច្ចកាល ប្រភេទនេះមានតែនៅតាមអាងទន្លេមេគង្គប៉ែកខាងលើប៉ុណ្ណោះ ។ អកត្រីក្បាលប្រផេះ (Grey-headed Fish Eagle *Icthyophaga ichthyaetus*) ត្រូវបានកត់ត្រាម្ដងដែរ ដែលជាប្រភេទមានវត្តមានមិនទៀងទាត់នៅក្នុងតំបន់នេះ ។ ដោយសារតំបន់នេះស្ថិតនៅជិតរាជធានីភ្នំពេញ ហើយងាយស្រួលទៅដល់ផងនោះ តំបន់ IBA នេះ មានសក្ដានុពលធំធេងសម្រាប់កម្មវិធីអប់រំផ្សព្វផ្សាយចំណេះដឹងលើការអភិរក្សសត្វព្រៃ ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| **ឈ្មោះខ្មែរ** | **ឈ្មោះអង់គ្លេស** | **ឈ្មោះវិទ្យាសាស្ត្រ** | **លក្ខណៈវិនិច្ឆ័យIBA** |
|---|---|---|---|
| ចាបពូកទ្រូងលឿង | Asian Golden Weaver | *Ploceus hypoxanthus* | A1 |
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 |
| ស្មោញ | Darter | *Anhinga melanogaster* | A1 |

## ការគំរាមកំហែងលើជីវៈចំរុះ

មានភូមិជាច្រើនដែលមានទីតាំងស្ថិតនៅជិតៗតំបន់ IBA នេះ ហើយសកម្មភាពរបស់មនុស្សជាច្រើនបង្កឱ្យមានការរំខានយ៉ាងខ្លាំងដល់ពពួកសត្វស្លាប ។ ការកើនឡើងនៃការចាក់លុបតំបន់ដីសើមនេះសំរាប់ការអភិវឌ្ឍន៍ផ្ទះសំបែងជាបញ្ហាមួយគួរអោយព្រួយបារម្ភ ។

## អនុសាសន៍

ការវាយតំលៃមួយគួរតែធ្វើឡើងនៅក្នុងតំបន់ដែលមានសក្ដានុពលនេះសម្រាប់ការអនុវត្តន៍សកម្មភាពអប់រំ និង ផ្សព្វផ្សាយចំណេះដឹងដល់អ្នកទេសចរណ៍ដែលបានធ្វើដំណើរមកពីរាជធានីភ្នំពេញ ដើម្បីមកលំហែកាយកំសាន្តនៅទីនោះ ។ ការអប់រំ

ផ្សព្វផ្សាយគួរធ្វើឡើងនៅក្នុងតំបន់នេះ ដោយផ្តោតលើប្រភេទសត្វដែលមករកស៊ីនៅទីនោះ ជាពិសេស ទុងប្រផេះ ហើយគួរតែធ្វើឡើងនៅក្នុងវត្តមួយដែលមានទីតាំងនៅក្បែរនោះដែរ ។

### ឯកសារយោង


Duckworth, J. W. and Hedges, S. (1998) Bird records from Cambodia in 1997, including records of sixteen species new for the country. *Forktail* 14: 29-36.

Goes, F. ed. (1999) Recent sightings. *Cambodia Bird News* 3: 39-43.

Goes, F. (1999) Les marais de la plaine des quatre bras. *Cambodia Bird News* 3: 44-51. (In French.)

Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Mundkur, T., Carr, P., Sun Hean and Chhim Somean (1995) *Surveys for large waterbirds in Cambodia, March-Apri l 1994.* Cambridge, UK: IUCN/SSC.

Scott, D. A. (1992) *Survey of Cambodian wetlands, 26 November to 5 December 1992*. Unpublished report.